# អំណាចគ្រប់គ្រងរដ្ឋ

# UNDERLYING ASSUMPTIONS AND POWER DYNAMICS



# តើហេតុអ្វីបានជាពលរដ្ឋសកលត្រូវ យល់ពីប្រព័ន្ធគ្រប់គ្រងរដ្ឋ ?

# ប្រព័ន្ធគ្រប់គ្រងរដ្ឋ



# ស្ថាប័នគ្រប់គ្រងរដ្ឋ



# ស្ថាប័នគ្រប់គ្រងរដ្ឋ



# ស្ថាប័ននីតិបញ្ញត្តិ



ព្រឹទ្ធសភា

- ព្រឹទ្ធសភា មានមុខងារ *ពិនិត្យឱ្យយោបល់* លើអត្ថបទច្បាប់ដែលអនុម័តដោយរដ្ឋសភា និងផ្តួចផ្តើមធ្វើសេចក្តីស្នើច្បាប់
- ព្រឹទ្ធសភា មានតួនាទីសំខាន់ពិនិត្យឡើងវិញរាល់អត្ថបទច្បាប់ទាំងឡាយដែលរដ្ឋសភាបានអនុម័តរួចហើយ
- មានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរដ្ឋាភិបាល
- រដ្ឋសភាមិនអាចបញ្ជូនច្បាប់ដែលខ្លួនបានអនុម័តរួចហើយឱ្យព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើជាផ្លូវការមុនពេលដាក់ឆ្លងព្រឹទ្ធសភាពិនិត្យបានឡើយ

# ស្ថាប័ននីតិបញ្ញត្តិ

- ព្រឹទ្ធសភាមាន*អំណាចត្រួតពិនិត្យ* ព្រមទាំងធ្វើអនុសាសន៍ទៅលើពង្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលត្រូវបានអនុម័តដោយរដ្ឋសភា ទោះបីជាព្រឹទ្ធសភាអាចធ្វើការបដិសេធ ឬស្នើឱ្យធ្វើវិសោធនកម្មទៅលើអត្ថបទច្បាប់ ព្រឹទ្ធសភាពុំមានអំណាចចាប់បង្ខំឱ្យរដ្ឋសភាទទួលយកអនុសាសន៍របស់ខ្លួនឡើយ
- ព្រឹទ្ធសភា សហការជាមួយរដ្ឋសភានិងរាជរដ្ឋាភិបាល ដើម្បីរៀបចំឱ្យបានចេញជារូបរាងនូវកម្មវិធីនិងប្រតិទិននៃការកសាងច្បាប់សម្រាប់ឆ្នាំនីមួយៗ
- ព្រឹទ្ធសភាផ្តល់យោបល់លើអត្ថបទច្បាប់ក្នុងរយៈពេលមួយខែយ៉ាងយូរដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់បើជាការប្រញាប់ឱ្យពិនិត្យ ហើយរយៈពេលនោះ ត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ

# ស្ថាប័ននីតិបញ្ញត្តិ

រដ្ឋសភា

- រដ្ឋសភា ជាអង្គការដែលមាននីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន
- រដ្ឋសភា *អនុម័ត*ផែនការជាតិ ថវិការដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការសន្យានានា ផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ
- រដ្ឋសភា អនុម័តយល់ព្រមលើឬលុបចោល សន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ការអនុម័តនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល
- សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់

# ស្ថាប័ននីតិបញ្ញត្តិ




- ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវទ្រង់ ព្រះមហាក្សត្រឡាយព្រះហត្ថលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ
- ករណីបើច្បាប់នេះ បានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ
- ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហត្ថលេខា ប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសឱ្យទាន់តាមពេលវេលាកំណត់ខាងលើ

# ស្ថាប័ននីតិបញ្ញត្តិ




ក្រុមប្រឹក្សាធម្មនុញ្ញ

- ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច *ធានាការពារ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់* ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ
- ក្រុមប្រឹក្សាធម្មនុញ្ញ មាន *សិទ្ធិពិនិត្យនិងសម្រេចអំពីករណីវិវាទកម្ម* ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

# ស្ថាប័ននីតិបញ្ញត្តិ

- បទបញ្ញាផ្ទៃក្នុងរដ្ឋសភា បទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើ
- ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងរយៈពេលសាមសិបថ្ងៃយ៉ាងយូរ ថាតើច្បាប់បទបញ្ញាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ
- បទប្បញ្ញត្តិក្នុងមាត្រាណា ដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឱ្យប្រើ ឬយកទៅអនុវត្តបានឡើយ
- *សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចបិទផ្លូវតវ៉ា*

# ស្ថាប័នតុលាការ






- អំណាចតុលាការជាអំណាចឯករាជ្យ
- អំណាចតុលាការត្រូវជានារក្សា និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ
- អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង
- អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់
- គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ
- ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ-ឧត្តមក្រុមប្រឹក្សាអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ

# ស្ថាប័ននីតិប្រតិបត្តិ



## នាយករដ្ឋមន្ត្រី

- រាជរដ្ឋាភិបាល ជាអង្គការនីតិប្រតិបត្តិ មានសមត្ថកិច្ច កំណត់ និងអនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ
- ត្រូវធានាការអនុវត្តន៍ច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការណាដែលជាសមត្ថកិច្ចរបស់អង្គការនីតិបញ្ញត្តិ និងអង្គការតុលាការ
- ត្រូវគ្រប់គ្រង បញ្ជា ប្រើប្រាស់រដ្ឋបាលសាធារណៈគ្រប់ថ្នាក់ រួមទាំងកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងកម្លាំងប្រដាប់អាវុធផ្សេងៗទៀត ក្នុងការធ្វើសកម្មភាពរបស់ខ្លួន